# ការសម្ភាសរបស់អ៊ុំស្រី អ៊ីន នី

**កៈ អ្នកសម្ភាសឈ្មោះជាង ស៊ីអ៊ាវ** **ខៈ អ្នកទទួលការសម្ភាសឈ្មោះ អ៊ីន នី។**

## ការសង្ខេបប្រវត្តិរបស់អ៊ុំស្រី អ៊ីន នី

អ៊ុំស្រី អ៊ីន នី មានអាយុ៥៦ឆ្នាំនៅក្នុងឆ្នាំ២០២០ មានកូន២នាក់ ស្រី១នាក់ ប្រុស១នាក់ មានទីលំនៅបច្ចុប្បន្ននៅភូមិទួលរកា ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំពិភាក្សាជាមួយអ៊ុំទាក់ទងពីប្រវត្តិរបស់អ៊ុំ ហើយការសម្ភាសទាំងអស់និងគឺរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់និងបានដឹងពីប្រវត្តិឪពុកម្ដាយនិងដូនតាជាពិសេសខ្ញុំសម្ភាសអ៊ុំទុកអោយចៅៗអ៊ុំបានស្គាល់បានដឹងចឹងហាណាស់អ៊ុំ?

ខៈ ចាស!

កៈ បាទ! ចឹងអ៊ុំយល់ព្រមខ្ញុំដាក់សម្ភាសមួយនិងទៅក្នុងវេបសាយសាលាទេអ៊ុំ?

ខៈ ចាស!

កៈ បាទអ៊ុំចឹងសំរាប់ខ្ញុំជាអ្នកសម្ភាសអ៊ុំខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ាវហើយថ្ងៃខែដែរខ្ញុំសម្ភាសអ៊ុំគឺនៅថ្ងៃទី២៧ខែ៧ឆ្នាំ២០២០ហើយការសម្ភាសនិងគឺធ្វើឡើងនៅភូមិអើទួលរកា ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាមចឹងសំរាប់អ៊ុំឈ្មោះពេញរបស់អ៊ុំតាមបញ្ជីជាតិហាស?

ខៈ ចាស!

កៈ ទាំងត្រកូលឈ្មោះអីគេអ៊ុំ?

ខ៖ អុីន នី។

ក៖ អុីន នីហោសអុំ?

ខ៖ ចាស!

ក៖ ចុះមានឈ្មោះហៅក្រៅអត់អុំ?

ខ៖ មាន។

ក៖ ឈ្មោះអីគេអុំ?

ខ៖ ហៅក្រៅគេហៅរាល់ថ្ងៃនិងហៅអុីប្រេងៗ។

ក៖ អុីប្រេង?

ខ៖ ចាស!

ក៖ អូ៎ចុះកាលពីនៅក្មេងៗមាននរណាគេហៅឈ្មោះអុំអីផ្សេងទៀតអត់?

ខ៖ អត់គ្មាននរណាគេហៅ។

ក៖ អត់ទេណោះអុំ?

ខ៖ ចាស!

ក៖ ចុះអុំសព្វថ្ងៃអុំអាយុប៉ុន្មានអុំ?

ខ៖ ខ្ញុំអាយុហាប្រាំមួយហើយ!

ក៖ ហាប្រាំមួយណេះអុំណេះ?

ខ៖ ចាស!

ក៖ ចុះអើហាប្រាំមួយចុះអើអុំកើតនៅឆ្នាំថ្ងៃខែឆ្នាំណាអុំចាំអត់?

ខ៖ អត់ចាំផង។

កៈ អ៊ូចុះអើអាលក្ខណៈថាឆ្នាំពីរពាន់ប៉ុន្មានៗក៏អត់ចាំដែរណោះអ៊ុំណោះ?

ខៈ អត់ដែរ។

កៈ អ៊ូ!

ខៈ ចាំតែឆ្នាំអាយុ។

កៈ ចឹងអ៊ុំកើតនៅឆ្នាំមួយពាន់ប្រាំបួនរយហុកបួនថ្ងៃខែអ៊ុំអត់ចាំទេចុះអាឆ្នាំជូត ឆ្លូវ ខាល ថោះអ៊ុំឆ្នាំអីគេអ៊ុំ?

ខៈ ចាស!

កៈ ឆ្នាំជូត ឆ្លូវ ខាល ថោះហាសអ៊ុំឆ្នាំអីគេទៅ?

ខៈ ខ្ញុំឆ្នាំរកា។

កៈ ឆ្នាំរកាណោះអ៊ុំណោះ?

ខៈ ចាស!

កៈ អ៊ូចុះអើស្រុកកំណើតដែរអ៊ុំកើតម៉ងអ៊ុំកើតនៅណាអ៊ុំ?

ខៈ ណោះកើតនៅពង្រ។

កៈ ទួលពង្រ?

ខៈ ចាស!

កៈ អាហ្នឹងឃុំ..?

ខៈ ឃុំរអាង។

កៈ ឃុំរអាងដែរហោស?

ខៈ ចាស!

កៈ ស្រុកកំពង់សៀម ខេត្តកំពង់ចាមយើង?

ខៈ ចាស!

កៈ បាទអ៊ុំចុះអ៊ុំមានបងប្អូនបង្កើតចំនួនប៉ុន្មាននាក់អ៊ុំ?

ខៈ បួននាក់។

កៈ បួននាក់អ៊ុំកូនទីប៉ុន្មានទៅ?

ខៈ ខ្ញុំកូនទីបី។

កៈ មានស្រីប៉ុន្មានប្រុសប៉ុន្មានអ៊ុំ?

ខៈ ស្រីបីប្រុសមួយ។

កៈ អូ៎ចុះអើអ៊ុំអាចប្រាប់ឈ្មោះបងប្អូនអ៊ុំបានទេថាពួកគាត់ឈ្មោះអីចឹងហាសណាស់?

ខៈ បានតើបងគេស្រីនោះឈ្មោះយាយហាន ទីពីរយាយហុន។

កៈ អូ៎!

ខៈ រួចមកខ្ញុំរួចពៅក្អឿន។

កៈ អូ៎បាទចុះអើទីមួយនិងយាយហានគាត់នៅណា?

ខៈ គាត់នៅពង្រ។

កៈ អូ៎កាត់ធ្វើអីគេទៅ?

ខៈ គាត់ឥឡូវនិងគាត់ធ្វើមើលគោទៅអីទៅ។

កៈ អូ៎គាត់មានកំលាំងមើលគោដែរ?

ខៈ ចាស!

កៈ គាត់អាយុប៉ុន្មានហើយអ៊ុំ?

ខ៖ កាត់ណុងអាយុមើលហាប្រាំបួនហើយ!

ក៖ ហាប្រាំបួន?

ខ៖ មើលគោគេចាស!

ក៖ អ៊ូបន្ទាប់មក?

ខ៖ បន្ទាប់មួយឆ្នាំមួយឆ្នាំមួយ។

ក៖ ចុះបន្ទាប់មកទៀតទីពីរ?

ខ៖ ទីពីរនៅរអាង។

ក៖ គាត់អាយុហាប្រាំបី?

ខ៖ ចាស! គាត់នៅចាំផ្ទះដែរ។

ក៖ អ៊ូ!

ខ៖ នៅជាមួយថៅ។

ក៖ អ៊ូដល់ពេលអ៊ុំហាប្រាំ?

ខ៖ ហាប្រាំមួយ។

ក៖ ប៉ុន្តែអ៊ុំមានថៅដែរតើហី?

ខ៖ មានថៅមួយពីរហើយថៅពីរហើយស្រីមួយប្រុសមួយ។

ក៖ អ៊ូថៅៗណុងហោស?

ខ៖ ថៅណុង។

ក៖ អ៊ូបាទអ៊ុំចុះអើអ៊ុំគិតថាអ៊ុំធ្លាប់មានអនុស្សាវរីយ៍ឬមួយក៏មានការចងចាំអីជាមួយបងប្អូនកាលនៅក្មេងៗអីអត់អ៊ុំ?

ខ៖ មានចងចាំអីបើបងប្អូនកើតមកនេះហោសនៅជាមួយឪពុកម្ដាយបាននៅតូចៗទេឪពុកម្ដាយស្លាប់អស់ទៅ។

ក៖ អូ៎!

ខ៖ ចាស! ចុះពីថ្លុកត្រែងមកអានេះគេជំលាសទៅនៅស្រុកត្រែង។

ក៖ បាទអ៊ំ!

ខ៖ ចុះពីថ្លុកត្រែងមកវិញឪពុកស្លាប់។

ក៖ អូ៎!

ខ៖ បានមួយឆ្នាំម្ដាយស្លាប់ទៀត។

ក៖ អូ៎នៅក្នុងជំនាន់ប៉ុលពតទាំងអស់?

ខ៖ សុទ្ធតែនេះណុងជំនាន់ប៉ុលពតហ្នឹង!

ក៖ គាត់ស្លាប់ដោយសារអីអ៊ំ?

ខ៖ គាត់ស្លាប់ដោយសារជំងឺឈឺចាញ់។

ក៖ អូ៎!

ខ៖ ចុះពីថ្លុកត្រែងមកវិញទិញពុះ។

ក៖ បាទអ៊ំ!

ខ៖ ចាញ់គាត់ចាញ់លោកតាងាប់ទៅឪពុកហោស!

ក៖ អូ៎បាទអ៊ំបាទ!

ខ៖ រួចម្ដាយទៀតមកឈឺរកអីស៊ីគ្មានជំនាន់ណុងគ្មានអីស៊ីទេ។

ក៖ ចឹងហោសអ៊ំ?

ខ៖ ចាស! រួចកូនប្អូននាក់ណោះគ្មានអីស៊ីរួចដល់ពេលនេះទៅគេបញ្ជូលជំលាសមកនៅក្នុងកុមារនិងនៅជាមួយបងនិងនៅក្នុងមន្ទីរកុមារហ្នឹងទៅ។

ក៖ បាទអ៊ុំ!

ខ៖ ទាំងប្អូននាក់បងប្អូនហ្នឹង!

ក៖ បាទអ៊ុំបាទ!

ខ៖ រួចឪពុកមានោះគេបាញ់សំលាប់ជំនាន់ប៉ុលពតហ្នឹងដែរទៅងាប់ទៅ។

ក៖ អូ៎បាទអ៊ុំ!

ខ៖ អូ៎អាណិតឪពុកមាណុងណាស់គេបាញ់ងាប់ហើយគេមិនសែងត្រឹមត្រូវទេគេចងដៃចងជើងសែងដូចជ្រូកចឹងយកទៅក្រវាត់ចោល។

ក៖ ម៉េចចឹង?

ខ៖ គេបាញ់ចោលជំនាន់អាពត។

ក៖ គាត់ធ្វើអីខុសមែន?

ខ៖ អត់ដឹងខ្ញុំនៅកុមារដែរ។

ក៖ ចឹងអ៊ុំក៏អត់ដឹងដែរណោះ?

ខ៖ ចាស! អត់ដឹងគាត់និងគាត់គេ..។

ក៖ អូ៎បាទអ៊ុំ!

ខ៖ ប៉ុនឃើញឃើញគេសែងយកទៅចោលកប់ចោលទៅ។

ក៖ បាទអ៊ុំចុះអ៊ុំគិតថាអើចឹងបងប្អូនរបស់អ៊ុំនៅបែកគ្នាទាំងអស់ឥឡូវណោះ?

ខ៖ នៅបែកគ្នាអស់ហើយ!

ក៖ ប៉ុន្តែគ្រាន់តែជិតៗគ្នាទេ?

ខ៖ ចាស! នៅរៀងៗខ្លួនបងមួយនៅរអាងទៅបងមួយនៅស្រែពង្រណុងទៅពីរនាក់ប្អូនពៅណុង។

ក៖ បាទអ៊ុំបាទចុះអ៊ុំគិតថាឪពុករបស់អ៊ុំឈ្មោះអីគេអ៊ុំ?

ខ៖ ឈ្មោះអ៊ីន។

ក៖ ឈ្មោះអ៊ីនណេះ?

ខ៖ ចាស!

ក៖ ឈ្មោះអីគេអ៊ីនអ៊ុំ?

ខ៖ អើឪគាត់មិនដឹងឈ្មោះអីទេនេះហ៊ាប។

ក៖ ហ៊ាបហេស?

ខ៖ ចាស! ហ៊ាបអ៊ីន។

ក៖ ហ៊ាប..?

ខ៖ ចំណែកម៉ែខ្ញុំណុងស្រឿនស៊នស្រឿន។

ក៖ ស៊នស្រឿន?

ខ៖ ចាស!

ក៖ អូ៎រួចចុះឪពុកម្ដាយរបស់អ៊ុំគាត់អ្នកស្រុកនៅណាអ៊ុំ?

ខ៖ ណុងនៅពង្រណុង។

ក៖ អូ៎!

ខ៖ ម៉ែ។

ក៖ ប៉ុន្តែអើឪពុករបស់អ៊ុំកាលគាត់នៅក្មេងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតចិញ្ចឹមកូនចៅអ៊ុំ?

ខ៖ គាត់ធ្វើស្រែធ្វើចំការហ្នឹង!

ក៖ អ៊ូ!

ខ៖ គាត់ជាអ្នករកត្រីរកសាច់ហ្នឹងគ្មានធ្វើអីទេគាត់គ្មានជំនួញជួញដាក់អីផង។

ក៖ បាទអ៊ុំ!

ខ៖ ចាស!

ក៖ តែគាត់កាចឬមួយក៏ស្លូតអ៊ុំ?

ខ៖ ប៉ាខ្ញុំកាចទេអើស្លូតទេម៉ែខ្ញុំក៏ស្លូតដែរ។

ក៖ អ៊ូប៉ុន្តែម្ដាយរបស់អ៊ុំគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតកូនចៅអ៊ុំ?

ខ៖ គាត់ធ្វើស្រែធ្វើចំការហ្នឹង!

ក៖ ដូចតែឪពុកអ៊ុំដែរហោស?

ខ៖ ចាស! ដូចតែគ្នាហ្នឹង!

ក៖ អ៊ូបាទអ៊ុំបាទប៉ុន្តែម្ដាយស្លូត?

ខ៖ ស្លូតទាំងអស់ឪពុកម្ដាយខ្ញុំហោស!

ក៖ បាទអ៊ុំបាទអ៊ុំមានចងចាំអនុស្សាវរីយ៍អីកាលអ៊ុំនៅជាមួយឪពុកម្ដាយអ៊ុំកាលនៅក្មេងៗអត់អ៊ុំធ្លាប់ធ្វើអីគេខ្លះជាមួយគ្នាចឹងហាសណាស់?

ខ៖ អើជំនាន់ណុងម៉ែឪនៅណុងនៅតូចៗមិនដឹងទេ។

ក៖ អ៊ូ!

ខ៖ ចាស!

ក៖ ចុះអ៊ុំគិតថាពុករបស់អ៊ុំគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលគាត់នៅក្មេងទៅអ៊ុំទេ?

ខ៖ នៅក្មេងៗណុងអត់ដឹងដូចអត់សួរដឹងដែរគាត់។

ក៖ អូ៎ចុះម្ដាយអីក៏អត់ដែរនិយាយអីដែរណោះ?

ខ៖ ចាស! មិនដែរអីទេ។

ក៖ អូ៎ចុះអ៊ុំគិតថាអើយាយតាខាងឪពុកគាត់ឈ្មោះអីគេអ៊ុំ?

ខ៖ អត់ដឹងដែរនេះខ្ញុំ។

ក៖ យាយតាខាងឪបុកអត់ស្គាល់ទាំងអស់ម៉ង?

ខ៖ ចាស!

ក៖ អត់ឈ្មោះគាត់អត់ស្គាល់ដែរអ៊ុំហោស?

ខ៖ ឈ្មោះអាលែងយាយឈ្មោះភាពណុងហាសឪពុកប៉ាខ្ញុំម៉ែយាយមិនដឹងឈ្មោះអីទៀតទេ។

ក៖ តាហ៊ាប?

ខ៖ បើខាងម៉ែខ្ញុំយាយស៊ិនណុង យាយស៊ិនតាកោះប្ដីគាត់តាកោះឈ្មោះតាកោះ។

ក៖ ប៉ុន្តែយាយឈ្មោះយាយស៊ិន?

ខ៖ ចាស!

ក៖ អានិងឪពុកម្ដាយខាងម្ដាយ?

ខ៖ អាហ្នឹងខាងម្ដាយ។

ក៖ យាយស៊ិនតាកោះ?

ខ៖ ចាស!

ក៖ ប៉ុន្តែកាត់អ្នកស្រុកកំពង់ចាមហ្នឹងណោះ?

ខ៖ ចាស!

កៈ តាកោះអ៊ុំល្អចុះអ៊ុំគិតថាអើអ៊ុំមករស់នៅហ្នឹងយូរនៅអ៊ុំ?

ខៈ ខ្ញុំមកនៅនិងយូរហើយមានគ្រួសារមកនៅហ្នឹង!

កៈ អ៊ុំរយៈពេលប៉ុន្មានឆ្នាំហើយអ៊ុំ?

ខៈ មើលកូនខ្ញុំមីស្រីហ្នឹងសាមខ្ញុំសាមសិបឆ្នាំហើយមកនៅស្រុកហ្នឹងហោស!

កៈ អ៊ុំយូរហើយណេះអ៊ុំណេះ?

ខៈ ចាស! អាដែងយូរហើយ!

កៈ អ៊ុំចុះកាលពីមុនណុងអ៊ុំនៅណាអ៊ុំ?

ខៈ នៅពង្រ។

កៈ នៅពង្រ?

ខៈ ចាស!

កៈ ដល់ពេលអ៊ុំមានគ្រួសារមកអ៊ុំមកនៅជាមួយគ្រួសារ?

ខៈ មកនៅហ្នឹងពេលមានគ្រួសារមក។

កៈ បាទអ៊ុំចុះមានបងប្អូនកូនចៅណាដែរទៅរស់នៅខេត្តផ្សេងអត់អ៊ុំ?

ខៈ អត់មានផង។

កៈ នៅសៀមរាបអីក៏អត់មានដែរ?

ខៈ គ្មានទេ។

កៈ ចុះ...?

ខៈ មីមួយនៅស្គន់កូនខ្ញុំ។

កៈ ណាមួយណា?

ខ៖ អាពៅមីខ្ញុំកូនតែពីរហ្នឹង!

ក៖ ស្រីមិញហ្នឹងហោស?

ខ៖ ណោះនៅស្តន់ហោសកូនខ្ញុំអាប្រុសហោស!

ក៖ អូ៎!

ខ៖ នៅជាមួយហ្នឹងនៅស្រីមីនៅដេរនៅភ្នំពេញ។

ក៖ បាទអ៊ុំ!

ខ៖ នេះចៅ។

ក៖ ចុះចឹងអ៊ុំអត់មានកូនចៅនៅជាមួយទេណេះ?

ខ៖ អត់មានទេនៅតែពីរនាក់ចៅនេះ។

ក៖ ហ្នឹងផ្ទះអ៊ុំហោស?

ខ៖ ចាស! ផ្ទះខ្ញុំហើយហ្នឹង!

ក៖ រួចចុះពួកគាត់នៅក្រោមណុងពីណាគេ?

ខ៖ ណុងក្មួយៗនៅផ្ទះហ្នឹងដែរ។

ក៖ អូ៎សុទ្ធអ្នកជិតៗហ្នឹង?

ខ៖ ចាស! ជិតៗហ្នឹង!

ក៖ អូ៎បាទអ៊ុំបាទ!

ខ៖ តែពីរនាក់ចៅនិងរាល់ថ្ងៃមេម៉ាយ។

ក៖ អូ៎ចុះតានៅណា?

ខ៖ គាត់ស្លាប់បាត់។

កៈ ស្លាប់យូរហើយហោស?

ខៈ ចាស! ស្លាប់យូរហើយ!

កៈ អ៊ូចុះតាឈ្មោះអីគេអ៊ុំ?

ខៈ ចាស!

កៈ ប្ដីរបស់អ៊ុំឈ្មោះអីគេ?

ខៈ ប្ដីខ្ញុំឈ្មោះតូច។

កៈ ប៉ុន្តែកើតអីបានគាត់ស្លាប់?

ខៈ គាត់ឈឺ។

កៈ គាត់ឈឺ?

ខៈ ចាស!

កៈ អ៊ូបាទអ៊ុំគាត់ស្លាប់យូរនៅ?

ខៈ យូរហើយតាំងពីម៉្ភៃឆ្នាំជាងហើយតាំងពីកូនខ្ញុំនៅតឡូវវាម៉្ភៃហើយ!

កៈ អ៊ូប៉ុន្តែអើដូចជាកើតអីបានគាត់ស្លាប់អ៊ុំ?

ខៈ ឈឺ។

កៈ ឈឺហោស?

ខៈ ចាស!

កៈ អ៊ូប៉ុន្តែពីមុននិងគាត់ស្លាប់និងគាត់អើគាត់ធ្វើអីគេអ៊ុំ?

ខៈ ហ្នឹងធ្វើស្រែធ្វើចំការធ្វើប្រាំងហ្នឹង!

កៈ ពេលគាត់ស្លាប់ចឹងអ៊ុំអ្នកធ្វើតែឯងទៅ?

ខ៖ ចាស!

ក៖ អ៊ូចឹងមានន័យថាអុំអាចធ្វើកើតណោះ?

ខ៖  ចាស! ឥឡូវនិងគ្មានធ្វើអីកើតទេមើលតែចៅមួយហ្នឹង!

ក៖ រួចទៅស្រែយើងធ្វើម៉េចទៅចឹង?

ខ៖ ប្រាំងឥឡូវនិងគេអត់ស្ទូងអត់អីទេព្រុះចោល។

ក៖ ព្រុះចោលទៅ?

ខ៖ ចាស!

ក៖ ដល់ពេលយើងទៅដល់ផលយើងទៅច្រូត?

ខ៖ ចាស! បានតិចៗរបបហោស!

ក៖ អ៊ូ!

ខ៖ មានអីច្រើន។

ក៖ បានប៉ុន្មានទៅអុំ?

ខ៖ របបស្រូវប្អូនដប់ថាំង។

ក៖ អ៊ូ!

ខ៖ សុទ្ធតែមាត់កណ្តុរមាត់អី។

ក៖ ប៉ុន្មានអារទៅ?

ខ៖ ដឹងប៉ុន្មានអារទេគេចឹកអោយ។

ក៖ អ៊ូ!

ខ៖ ចាស!

កៈ បាទអ៊ុំចុះអ៊ុំការនិងអស់ប៉ុន្មានឆ្នាំហើយអ៊ុំ?

ខៈ ខ្ញុំការហោស?

កៈ បាទ!

ខៈ សាមសិបឆ្នាំហើយ!

កៈ កូនអ៊ុំកូនបងអាយុប៉ុន្មានទៅ?

ខៈ កូនបងខ្ញុំនិងអាយុអើម្ល៉ែឆ្នាំអើម្ល៉ែមើលម្ល៉ែប្រាំពីរម្ល៉ែប្រាំបីឆ្នាំហើយកូនខ្ញុំ។

កៈ ឆ្នាំអីគេអ៊ុំ?

ខៈ ឆ្នាំមមី។

កៈ មមីហោស?

ខៈ ចាស!

កៈ មមីសាមហើយ?

ខៈ ចាស! មមីសាមហើយចឹង។

កៈ សាមសាមមួយហើយ?

ខៈ ចាស! កូនខ្ញុំនេះម៉ែអានេះ។

កៈ អ៊ំស្រីទាំងពីរហោសអ៊ុំ?

ខៈ ស្រីមួយប្រុសមួយ។

កៈ អ៊ំប៉ុន្តែចៅប៉ុន្មាននាក់អ៊ុំ?

ខៈ ចៅតែមួយហ្នឹង!

កៈ ចៅតែមួយហ្នឹងទេហោស?

ខ៖ តែមួយហ្នឹងនៅជាមួយ។

ក៖ ប៉ុន្តែអើម្ដាយរបស់ពួកគាត់និងនៅភ្នំពេញអុំ?

ខ៖ ចាស!

ក៖ គាត់ធ្វើអីគេ?

ខ៖ ដេរ។

ក៖ ចុះប្ដីគាត់ហោស?

ខ៖ ប្ដីគាត់នៅហ្នឹង។

ក៖ នៅហ្នឹងហោស?

ខ៖ ចាស!

ក៖ គាត់ជួយធ្វើស្រែធ្វើប្រាំងយើងហោស?

ខ៖ ធ្វើប្រាំង។

ក៖ អើម៉េចអត់នៅជាមួយគ្នាចឹងអុំ?

ខ៖ នេះហ្នឹងវាមកលេង។

ក៖ អូ៎!

ខ៖ នេះមកលេងកូននេះ។

ក៖ ដល់ពេលហើយគាត់ឡើងទៅវិញទៅ?

ខ៖ ឡើងទៅវិញទៅ។

ក៖ ដល់ពេលឡើងទៅវិញគាត់ធ្វើអីគេអុំ?

ខ៖ ឡើងទៅវិញវានេះដេរធ្វើការដេរ។

ក៖ អ៊ំបាទចុះកូនមួយទៀត?

ខ៖ កូនមួយទៀតវានៅនេះណុងខាងស្គន់។

ក៖ នៅស្គន់?

ខ៖ ចាស!

ក៖ គាត់ធ្វើអីគេនៅណុង?

ខ៖ ធ្វើណុងវាខាងជាងខាងផ្សារដែកផ្សារអី។

ក៖ តែគាត់មានគ្រួសារមានប្រពន្ធនៅ?

ខ៖ មានកូនមួយហើយ!

ក៖ អ៊ំមានកូនមួយដែរហោស?

ខ៖ ចាស!

ក៖ គាត់នៅជាមួយគ្រួសារគាត់នៅណុងហាសណេះ?

ខ៖ ចាស!

ក៖ ចឹងអត់មាននរណាគេនៅជាមួយអ៊ំទេចឹង?

ខ៖ អត់មានទេនៅតែឯងពីរនាក់ថៅ។

ក៖ អ៊ំបាទអ៊ំចុះអ៊ំគិតថាអើដូចជាកាលអ៊ំការជាមួយប្ដីរបស់អ៊ំនិងដូចជាអ៊ំចិត្តចង់រៀបដោយខ្លួនឯងឬមួយក៏ឪពុកម្ដាយអ្នករៀបចំអោយយើងពេលណុង?

ខ៖ ពេលណុងហោស?

ក៖ បាទអ៊ំ!

ខ៖ ឪពុកម្ដាយរៀបចំអោយ។

កៈ អ៊ូ!

ខៈ ចាស!

កៈ ប៉ុន្តែអើដូចជាអ៊ុំស្គាល់គ្នាពីមុននៅ?

ខៈ អត់ទេ។

កៈ អត់ដែរស្គាល់គ្នាផងណោះអ៊ុំណេះ?

ខៈ ចាស!

កៈ អ៊ូបាទអ៊ុំជំនាន់ណុងមានជាថ្លៃទឹកដោះថ្លៃបណ្ណាការអត់អ៊ុំ?

ខៈ មានប៉ុន្មានរយទេកាលណុងប៉ុន្មានដូចប្រាំបួនរយលុយយើងហ្នឹង!

កៈ ប្រាំបួនរយលុយខ្មែរហោស?

ខៈ ចាស! យូរហើយ!

កៈ អ៊ូកាលណុងលុយថ្លៃណេះអ៊ុំ?

ខៈ ចាស! លុយថ្លៃ។

កៈ អ៊ូ!

ខៈ កាលណុងយើងមួយកាក់ពីរកាក់ហាស!

កៈ បាទអ៊ុំបាទចុះអើអ៊ុំគិតថាកាលជំនាន់អ៊ុំកាលនិងជាការដូចយើងឥឡូវដែរឬមួយក៏ម៉េចអ៊ុំ?

ខៈ ការដូចយើងឥឡូវដែរនិងប៉ុន្តែថានេះគ្មានរោងគ្មានអីចឹងទេគេធ្វើរោងដែរប៉ុន្តែថាប្រកប៉ាត ង់ទៅប្រកស្លឹកអីទៅរោងហោស!

កៈ បាទអ៊ុំ!

ខៈ ចាស!

កៈ ចុះអ៊ុំគិតថាអ៊ុំធ្លាប់បានរៀនអត់អ៊ុំ?

ខៈ កុំមាត់ៗ។

កៈ អ៊ុំធ្លាប់បានរៀនខ្មែរពីមុនទេអ៊ុំ?

ខៈ ខ្ញុំរៀនជំនាន់ប៉ុលពតណុងប៉ុនមិនចេះផង។

កៈ អូ៎ណុងគេហៅរៀនអីគេរៀនអក្ខរៈកម្ម?

ខៈ រៀនហ្នឹងហើយរៀនអក្ខរៈកម្មណុង។

កៈ តែយើងរៀនអត់សូវចេះទេណេះអ៊ុំ?

ខៈ អត់ចេះចាស! រៀនអត់ចេះ។

កៈ អូ៎បាទអ៊ុំបាទចុះប៉ុន្តែបារាំងអីអ៊ុំអត់បានរៀនទេ?

ខៈ អត់ចេះទេ។

កៈ ភាសាផ្សេងអី?

ខៈ អត់។

កៈ អូ៎បាទអ៊ុំ!

ខៈ តែខ្មែរនិងមិនចេះផង។

កៈ កាលអ៊ុំរៀននិងរៀននៅណាអ៊ុំ?

ខៈ រៀនៅនេះយើងនិងរអាង។

កៈ អូ៎!

ខៈ ជំនាន់អាពតគេដាក់កុមារម្តុំៗហោស?

កៈ បាទអ៊ុំចុះកាលអ៊ុំរៀននិងអ៊ុំធ្លាប់មានមិត្តភក្តិស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាអត់អ៊ុំ?

ខ៖ មានតែគគោកដៃរដល់ពេលនេះទៅបែកខ្ញែកគ្នាទៅបែកគ្នាអស់រលីងហើយ!

ក៖ អ៊ំប៉ុន្តែគាត់អ្នកស្រុកនិងដែរតើហី?

ខ៖ ចាស! សុទ្ធតែនៅស្រុកនិងទាំងអស់គ្នា។

ក៖ អ៊ំល្អចុះអ៊ុំគិតថាទាក់ទងពីអ៊ុំធ្លាប់មានអនុស្សាវរីយ៍ជាមួយមិត្តភក្តិកាលអ៊ុំនៅរៀនអត់អ៊ុំធ្លាប់ធ្វើការងារអីគេខ្លះជាមួយគាត់អត់?

ខ៖ ចាំចាបជំនាន់អាពត។

ក៖ អ៊ំចាំចាបហោស?

ខ៖ គ្មានធ្វើអីចាំចាប។

ក៖ អ៊ំចុះអើចឹងអ៊ុំធ្លាប់ធ្វើស្រែចំការណោះអ៊ុំណោះ?

ខ៖ ចាស! ចាំចាបជំនាន់អាពត។

ក៖ ប៉ុន្តែកាលនៅក្មេងអ៊ុំធ្លាប់ធ្វើស្រែចំការណោះអ៊ុំ?

ខ៖ ចាស!

ក៖ ភាគច្រើននៅស្រែអ៊ុំដកស្ទូង..?

ខ៖ ធ្វើស្រែ។

ក៖ ច្រូតកាត់អីចឹងហាសណោះ?

ខ៖ ណុងហើយ!

ក៖ ភ្ជួររាស់អ៊ុំអត់ចេះទេហី?

ខ៖ ភ្ជួររាស់អត់ចេះទេចេះតែដកស្ទូង។

ក៖ អ៊ំបាទអ៊ុំបាទចុះអ៊ុំគិតថាអើអ៊ុំធ្លាប់ធ្វើអាជីវកម្មអីខ្លះអ៊ុំ?

ខ៖ ឥឡូវហ្នឹងហោស!

ក៖ ពីមុន?

ខ៖ អើគ្មានធ្វើអីទេធ្វើតែស្រែហ្នឹងហាស!

ក៖ ធ្វើតែស្រែទេណោះអ៊ុំណោះ?

ខ៖ ចាស! ធ្វើតែស្រែគ្មានដែរធ្វើអីទេ។

ក៖ អ៊ូ៎ចុះអើលក់ដូរអ៊ុំធ្លាប់លក់ដូរទេ?

ខ៖ ធ្លាប់តើលក់ខ្មៅលក់អីហ្នឹង!

ក៖ អ៊ូ៎!

ខ៖ ដល់ពេលមកចាស់និងទៅលែងទៅរួចទៅឱបកង់ទៅលក់អីស្រែហោស!

ក៖ អ៊ូ៎ជឺកកង់យកទៅលក់ហោស?

ខ៖ ចាស!

ក៖ បាទអ៊ុំបាទចុះទាក់ទងពីការចិញ្ចឹមសត្វវិញអ៊ុំធ្លាប់ចិញ្ចឹមសត្វអត់អ៊ុំពីមុន?

ខ៖ ធ្លាប់តែចិញ្ចឹមជ្រូក។

ក៖ ជ្រូក មាន់ ទា គោ ក្របីណោះអ៊ុំណោះ?

ខ៖ ចាស! គោ។

ក៖ តែឥឡូវអ៊ុំឈប់ចិញ្ចឹមហើយណោះអ៊ុំណោះ?

ខ៖ ឥឡូវនិងឈប់ចិញ្ចឹមហើយជ្រូកនៅតែគោមួយ។

ក៖ អ៊ូ៎!

ខ៖ មានមេគោមួយ។

កៈ បាទអ៊ុំបាទអ៊ុំនៅចិញ្ចឹមគោហោសអ៊ុំហោស?

ខៈ ចាស! គោមេមួយ។

កៈ បាទអ៊ុំចុះអ៊ុំតាំងពីក្មេងរហូតមកដល់ឥឡូវការងារអីគេខ្លះដែរអ៊ុំធ្លាប់ធ្វើទៅអ៊ុំ?

ខៈ អ៊ុំខ្ញុំការងារដូចប្រុសចឹងតែឯងកាប់អុសលក់ក៏មានអីក៏មានសព្វគ្រប់។

កៈ អ៊ុំ!

ខៈ ការងារ។

កៈ បាទអ៊ុំបាទ!

ខៈ ប្រវត្តិតស៊ូមកចិញ្ចឹមកូន។

កៈ ពេលអ៊ុំមានគ្រួសារ?

ខៈ ចិញ្ចឹមកូនតែឯងចាស! អត់ពីគ្រួសារទៅរកចិញ្ចឹមកូនកូននៅតូចៗគាត់ស្លាប់ទៅ។

កៈ បាទអ៊ុំបាទចុះអ៊ុំគិតថាអើទាក់ទងពីការផ្លាស់ប្តូរវិញអ៊ុំគិតថាជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរអីគេខ្លះទៅអ៊ុំតាំងពីក្មេងរហូតមកដល់ឥឡូវ?

ខៈ តាំងពីក្មេងមករហូតដល់ឥឡូវហ្នឹងដូចគ្មានផ្លាស់ប្តូរថាដូចថាអោយធូរធារអីគ្មានទេមើលតែផ្ទះអ៊ុំដឹងហើយភ្លៀងមកសាចរកតែកន្លែងដេកមិនចង់បានទេ។

កៈ ចឹងដោយសារតែអ៊ុំនៅតែពីរនាក់ចៅទេណោះអ៊ុំណោះ?

ខៈ ពីរនាក់ចៅ។

កៈ អ៊ុំបាទអ៊ុំអ៊ុំម្ហូបអីដែរអ៊ុំចូលចិត្តហូបអ៊ុំ?

ខៈ ម្ហូបអីម្ហូបអីក៏បានដែរអោយតែមានហូបបានទាំងអស់ហ្នឹង!

កៈ អ៊ុំបាទអ៊ុំ!

ខៈ ចាស! តែប៉ុណ្ណឹងទេយើងអ្នកស្រុកស្រែស្រុកចំការហោស!

កៈ បាទអ៊ុំបាទចុះអ៊ុំគិតថាល្បែងប្រជាប្រិយ៍អីដែរអ៊ុំចូលចិត្តលេងតាំងពីក្មេងរហូតមកដល់ឥឡូវហាស?

ខៈ អើវាស្អីមិនចេះនិងគេទេ។

កៈ អត់ទេលក្ខណៈដូចបោះអង្គុញ ចោលឈូង..?

ខៈ អើ..!

កៈ លាក់កន្សែង ទាញព្រាត់អីហាស?

ខៈ ចាស! រាំវ៉ៃកអីទៅមើលតែគេអីទៅ។

កៈ អូ៎!

ខៈ តាំងពីក្មេងមកលេងឈូងលេងទាញព្រាត់អីហ្នឹង!

កៈ តែបើច្រៀងអីអ៊ុំចេះអត់?

ខៈ ខ្ញុំអត់ចេះទេ។

កៈ អត់ចូលចិត្តទេណោះអ៊ុំណោះ?

ខៈ ចាស!

កៈ ចុះអើរាំអីអ៊ុំចូលចិត្ត?

ខៈ ចាស! រាំអីចូលចិត្តដែរ។

កៈ ចុះអ៊ុំធំមកកាន់សិល្ប៍អីអ៊ុំកាន់សិល្ប៍ហាសណោះអ៊ុំ?

ខៈ នៅទេមិនទាន់ត្រូវចូលវត្តចូលអីនិងគេទេឥឡូវហ្នឹង!

កៈ អូ៎!

ខៈ ថាប្រុងនិងទៅដែរប៉ុន្តែថានៅតែឯងចឹងក៏ណារកម្ហូប។

កៈ វាពិបាក?

ខៈ អើរកម្ហូបរកអាហារអោយ។

កៈ បាទអ៊ុំបាទរួចចុះល្ខោនយីកេអាយ៉ៃង៉ុំចូលចិត្តទេអ៊ុំ?

ខៈ ខ្ញុំចូលចិត្តមើលតើល្ខោនដើរមើល។

កៈ ចឹងហោសអ៊ុំ?

ខៈ ចាស!

កៈ ចុះអ៊ុំគិតថាអ៊ុំមាននរណាគេមួយនៅក្នុងក្រុមគ្រួសារអ៊ុំចេះលេងឧបករណ៍ភ្លេងទេអ៊ុំ?

ខៈ អត់ចេះទេ។

កៈ ភ្លេងខ្មែរភ្លេងសៀមភ្លេងពិនពាតអីអត់ចេះទេហោសអ៊ុំ?

ខៈ អត់ចេះទាំងអស់។

កៈ អូ៎!

ខៈ អត់ចូលចិត្តអត់ចេះទេ។

កៈ បាទអ៊ុំបាទចុះទាក់ទងពីផ្ទះរបស់អ៊ុំមានលក្ខណៈបែបណាអ៊ុំ?

ខៈ ផ្ទះខ្ញុំហាសហ្នឹង!

កៈ ចុះកាលអ៊ុំនៅជាមួយឪពុកម្ដាយផ្ទះម៉េចអ៊ុំ?

ខៈ អើនៅជាមួយឪពុកម្ដាយខ្ញុំផ្ទះប្រកស្បូវពីដើម។

កៈ អូ៎!

ខៈ ជំនាន់ណុង។

កៈ បាទអ៊ុំបាទដល់ពេលមកដល់ឥឡូវ?

ខ៖ មកដល់ឥឡូវប្រកដែកផ្ទះតែឯង!

ក៖ ប្រកដែកនិងឈើប៉ុន្តែនៅកាលពីមុនក៏ផ្ទះនិងដែរណោះអ៊ុំណោះផ្ទនៅហ្នឹងដែរណោះ?

ខ៖ ខ្ញុំផ្ទះនៅតែហ្នឹង!

ក៖ អូ៎!

ខ៖ ប៉ុនអានេះនៅជាមួយម្ដាយទៅដល់ពេលអត់ពីគាត់និងទៅធ្វើផ្ទះខ្លួនឯងនៅចឹងទៅ។

ក៖ អូ៎បាទ!

ខ៖ យូរឆ្នាំហើយផ្ទះហ្នឹងបាស!

ក៖ បាទអ៊ុំបាទចុះអ៊ុំគិតថាអើដូចជាផ្ទះនិងនរណាគេជាអ្នកសាងសងជួសជុលវាអ៊ុំ?

ខ៖ ជួសជុលតែខ្លួនឯងនិងមានកូនណាបើគេមានបែកគ្រួសារទៅអស់ហើយ!

ក៖ ប៉ុន្តែអ៊ុំអត់មាននរណាគេចេះធ្វើផ្ទះទេណោះអ៊ុំ?

ខ៖ អត់។

ក៖ តែផ្ទះនិងគេប្រើឧបករណ៍អីខ្លះអ៊ុំ?

ខ៖ ផ្ទះហ្នឹង?

ក៖ បាទ!

ខ៖ គេប្រើរណាគេប្រើដែកឈូសទៅ។

ក៖ បាទអ៊ុំ!

ខ៖ អើ!

ក៖ ឈើហើយហ្នឹង..?

ខ៖ ប្រើឈើនិងដែកហ្នឹង!

កះ ប្រកដៃកប្រកអីណោះអ៊ុំណោះ?

ខះ ចាស!

កះ អូ៎បាទអ៊ុំបាទចុះអ៊ុំគិតថាតាំងពីក្មេងរហូតមកដល់ឥឡូវហោសដូចជាឪពុកម្តាយអ៊ុំធ្លាប់បង្រៀនពីជំនាញអីមួយទៅអ៊ុំអត់?

ខះ គ្មានទេកាលគាត់ស្លាប់ទៅនៅតូចៗដែរមិនដឹងជាមានអីផង។

កះ អូ៎បាទអ៊ុំបាទ!

ខះ វាគ្មានទៅណាទេ។

កះ អត់ទេណោះអ៊ុំណោះ?

ខះ ចាស! អត់ពីគាត់ទៅណុងចូលជំនាន់អាពតតែម៉ង។

កះ អូ៎ចុះឥឡូវសួរទាក់ទងពីជំនាន់ប៉ុលពតដូចជាអ៊ុំទាន់ជំនាន់លុនណុលណោះអ៊ុំណោះ?

ខះ អើជំនាន់លុនណុលនិងខ្ញុំឈឺដេកតែកន្ទេល។

កះ អូ៎!

ខះ គេចូលក្នុងរូងអស់កាលណុងទំលាក់គ្រាប់បែកហោស!

កះ បាទអ៊ុំបាទ!

ខះ គេចូលក្នុងរូងអស់ខ្ញុំនៅតែលើគោកក្នុងក្រោមជង្រុកណុង។

កះ អត់អីដែរ?

ខះ គ្មានអីទេតែគេឡើងពីក្នុងនេះទៅដូចថាទំលាក់ស្ងប់គេឡើងចឹងទៅគេបោសដីអោយទៅដីប៉ើងទៅសុទ្ធតែដីទៅ។

កះ អូ៎!

ខះ ឈឺប៉ុននរណាថារស់ទេទើបតែឥឡូវទេ។

កៈ បាទអ៊ុំចុះប៉ុន្តែគ្រាន់ថាយើងរកស៊ីយើងតែធ្វើស្រែធ្វើចំការធម្មតាហាសណោះអ៊ុំណោះ?

ខៈ ចាស! ធ្វើស្រែធ្វើចំការធម្មតា។

កៈ តែគ្រាន់ថាយប់ឡើងអីនាំគ្នាអើចូលទៅក្នុងត្រង់សេ?

ខៈ ចាស! ណុងអោយតែលឺយន្តហោះ។

កៈ អូ៎!

ខៈ នេះរកអត់បានហ្នឹងគេទេ។

កៈ ប៉ុន្តែនៅស្រុកយើងអត់អីទេណោះអ៊ុំណោះ?

ខៈ ចាស!

កៈ អត់មានត្រូវឆេះផ្ទះឆេះអី?

ខៈ អត់ទេគ្មានទេ។

កៈ អូ៎ស្រួលដែរចឹងចុះរហូតដល់បានចូលដល់ជំនាន់ប៉ុលពតពេលដែរដាច់លុនណុលមកបានចូលប៉ុលពតណោះអ៊ុំណោះ?

ខៈ ចាស!

កៈ ចុះប៉ុលពតអ៊ុំមានការលំបាកអីហើយគេជំលាសអ៊ុំទៅណាទៅ?

ខៈ ជំលាសពីស្រែណុងមកនៅរអាងហ្នឹង!

កៈ អូ៎បាទអ៊ុំ!

ខៈ នៅកុមារអានេះម្ដុំអានោះម្ដុំ។

កៈ អាយុប៉ុន្មានហើយពេលណុង?

ខៈ អើមិនដឹងអាយុប៉ុន្មានទេជំនាន់អាពតណុងមិនដឹងទេ។

ក៖ អ៎ូប៉ុន្តែគ្រាន់ដឹងថាអើកាលជំនាន់ប៉ុលពតនិងគេអោយយើងធ្វើអីខ្លះទៅអ៊ុំ?

ខ៖ ខ្ញុំចាំចាបទៅខ្ញុំចាំតែចាបទេ។

ក៖ អ៎ូចាំចាបហោស?

ខ៖ ចាស! គេអោយលើកទំនប់លើកអីទៅរែកបង្គីមិនរួចទេនៅតូច។

ក៖ អ៎ូចុះចឹងយើងចាំចាបរហូតបីឆ្នាំហ្នឹងម៉ង?

ខ៖ ចាស! ចាំតែចាបទៅ។

ក៖ ចុះចឹងយើងចេញពីណាចេញពីស្រែមកណាមករអាង?

ខ៖ នេះមកចាំចាបនិងរួចនិងមកនៅនេះរអាងផ្ទះនេះ។

ក៖ អ៎ូ!

ខ៖ កាលណុងផ្ទះនេះផ្ទះមីស្រីអាអីលក់អានាតហោសណុងផ្ទះណុងគេដាក់កុមារ។

ក៖ អ៎ូចុះអើអ៊ុំគិតថារបបអាហារយើងម៉េចដែរ?

ខ៖ អើយហូបបបរកាលណុងបបរមែនបបរសុទ្ធទេបបរលាយពោតហោស!

ក៖ អ៎ូ!

ខ៖ លាយពោតក្រហម។

ក៖ អ៎ូពិបាកហាសចឹងហោស?

ខ៖ អ៎ូពិបាកជំនាន់អាពត។

ក៖ ចុះការងារយើងគេអោយចាំតែចាបចឹងទៅ?

ខ៖ ចាំតែចាបចាំចាបចិញ្ច្រាំជី។

ក៖ ចិញ្ច្រាំជីអាចម៍គោអីហ្នឹងហោស?

ខ៖ ចិញ្ច្រាំជីនេះស្លឹកឈើហោសកាប់ដើមឈើដើមព្រៃចិញ្ច្រាំ។

ក៖ អូ៎ប៉ុន្តែយើងធ្វើពីព្រឹកទល់ល្ងាចតើអ៊ុំហោស?

ខ៖ ហ្នឹងហើយធ្វើនេះរួចទៅទៅបោះបាយពេលបាយបាយទៅបាយរួចមកវិញមកចិញ្ច្រាំទៀត។

ក៖ រួចចុះនៅពេលដែរយើងឈឺធ្វើម៉េចអ៊ុំ?

ខ៖ ឈឺកាលណុងគេអោយថ្នាំលេបអីដែរប៉ុនដូចគ្មានឈឺអីទេជំនាន់អពតណុងដូចខ្លាចឹងមែនដូចឥឡូវហ្នឹងណា។

ក៖ អូ៎បាទរួចុះអើដូចជាបងប្អូនឬមួយក៏ឪពុកម្តាយគាត់ជំលាសទៅណាទៅ?

ខ៖ តែឪពុកម្តាយងាប់អស់ហើយជំនាន់អាពតកាលហ្នឹង!

ក៖ អូ៎គាត់ស្លាប់ហើយហោស?

ខ៖ ចាស!

ក៖ ចឹងថាអ៊ុំនៅតែប៉ុន្មាននាក់បងប្អូនទេ?

ខ៖ ហ្នឹងហាសនៅប្អូននាក់បងប្អូននៅកុមារទាំងអស់ហ្នឹង!

ក៖ អូ៎ប៉ុន្តែគេជំលាសទៅនៅផ្សេងៗគ្នាហី?

ខ៖ បងស្រីទៅហៃងចល័តទៅគាត់ធំជាងគេបងស្រីយាយបានហ្នឹង!

ក៖ បាទអ៊ុំបាទ!

ខ៖ នៅយាយហុនមួយនិងនៅគ្រប់គ្រងប្អូនបីនាក់នៅក្នុងកុមារហ្នឹង!

ក៖ អូ៎!

ខ៖ ចាស! យប់ឡើងនាំបងប្អូនដេកទៅ។

ក៖ អូ៎ចឹងមានន័យថាពេលយើងជំលាសនិងយើងមកនៅជុំបងប្អូនអស់ហើយ?

ខ៖ ចាស! ជុំបងប្អូនបែកតែបងស្រីមួយទេគាត់ធំជាងគេទៅខាងចល័ត។

ក៖ បាទអ៊ុំ?

ខ៖ ចាស!

ក៖ ចុះអ៊ុំគិតថាចឹងសំរាប់ដូចជាយើងអត់មានមកត្រូវទៅណាទៀតទេវាជំលាសមកតែខាងរអាងហ្នឹងហើយ..?

ខ៖ នៅតែម្តុំណុងទេ។

ក៖ ចុះបងៗគាត់ធ្វើអីគេ?

ខ៖ បងស្រីខ្ញុំធ្វើចល័ត។

ក៖ ប៉ុន្តែបងទីពីរ?

ខ៖ បងទីពីរនៅកុមារដែរនៅជាមួយខ្ញុំណុងដែរ។

ក៖ ចាំចាបដែរចឹងទៅ?

ខ៖ គាត់នៅចាំចាបដែរ។

ក៖ គ្រាប់យើងចាំតំបន់ខុសគ្នាហីអ៊ុំ?

ខ៖ ណុងខុសៗគ្នាម្តុំៗម្នាក់ចឹងទៅ។

ក៖ អូ៎ចុះបន្ទាប់ពៅអី?

ខ៖ បន្ទាប់អាពៅនៅតូចជាងគេអត់ទៅណាទេមកនៅជាមួយបងខ្ញុំទៅជួយចាំចាបហ្នឹងគេទៅកាលណុងគ្រូណុងគាត់អើអាណិតដែរប្អូនប្រុសណុងដូចថាអត់មានឪពុកម្តាយចឹងទៅនៅជាមួយគេគេអោយយកមកនៅជាមួយគ្នាក្នុងកុមារណុងដែរទៅ។

ក៖ បាទអ៊ុំបាទ!

ខ៖ ចាស!

កៈ អ៊ូស្រួល!

ខៈ ស្រួលដែរជំនាន់អាពតណុង។

កៈ បាទអ៊ីុចុះអ៊ីុគិតថាធ្វើម៉េចបានយើងដឹងថាដាច់ប៉ុលពតអ៊ីុ?

ខៈ ដាច់ប៉ុលពតណុងហោស?

កៈ បាទ!

ខៈ កាលណុងបានវៀតណាមគាត់វ៉ៃលុកមកបានដាច់ហ្នឹងទៅបានរត់ទៅពង្រវិញខ្ញុំហោស!

កៈ អ៊ូបាទអ៊ីុ!

ខៈ រត់ទៅពង្រវិញជួបជុំបងប្អូននៅពង្រណុងទៅ។

កៈ បាទអ៊ីុ!

ខៈ បានគុណវៀតណាមណុងដែរគាត់ខាងរំដោះ។

កៈ គេមកប្រាប់យើងឬមួយក៏ម៉េចអ៊ីុ?

ខៈ ហេ៎ដូចគ្មានពីណាប្រាប់ទេដូចគេរត់ទៅឯងក៏រត់ទៅតគ្នារត់ៗជាមួយគ្នាទៅ។

កៈ ប៉ុន្តែពេលយើងមកនិងអត់ឃើញមានប៉ុលពតអីវាទេណោះ?

ខៈ អត់ទេ។

កៈ គេវ៉ៃប៉ុលពតចូលព្រៃអស់ហើយណោះ?

ខៈ ហ្នឹងហើយគេរត់អស់ទៅយើងរត់ទៅដណ្តើមគ្នាអាណាកាប់អាលែងកាលណុងមន្ទីរគេដាក់ជង្រុកស្រូវអាណាកាប់ៗទៅបើខ្ញុំបីប្អូននាក់បងប្អូននិងទៅលើកនិងគេម៉េចរួចនៅតូចហោសដូចកាលណុងមានរោងឃាមចឹងហាសនាំបងប្អូនណុងកើបស្រូវនិងគេយកមកដាក់ការ៉ុងរួចឃាមចឹងអត់យកទៅណាទេរួចមិនដឹងយកទៅទុកអីណារួចមានហ៊ានយកច្រើនទេខ្លាចគេវ៉ៃចោល។

ក៖ អ៊ំបាទ!

ខ៖ យកបានតែតិចៗមកជាមួយបងប្អូនណុងផ្ទះនេះ។

ក៖ អ៊ំបាទអ៊ុំបាទ!

ខ៖ អ៊ំយកំសត់កំរណាស់រួចចាននោះគ្មានអីទេបីបួននាក់បងប្អូននិងអើកាលណុងចានកាលណុងចានប្រើចានដែកធ្លុះៗដាក់នេះចឹងទៅដាក់វាផ្អៀងវាមួយចំហៀងចេះដួសហុតមួយចំហៀងទៅស្រូបហោសចឹង។

ក៖ អ៊ំបាទអ៊ុំប៉ុន្តែគ្រាន់ថាយើងរបបវារៀងពិបាកយើងហូបបបរណោះអ៊ុំ?

ខ៖ ចាស! រៀងពិបាកហូបបបរ។

ក៖ អ៊ំចុះនៅពេលដែរយើងរ៉ែដាច់យើងពេលដំបូងៗយើងចាប់ផ្តើមធ្វើអីគេទៅធ្វើស្រែរួមអ៊ុំហោស?

ខ៖ កាលណុងធ្វើរួមក្រុមៗវាតាមក្រុមៗចឹងហាស!

ក៖ បាទអ៊ុំបាទ!

ខ៖ ដកស្ទូងទៅ។

ក៖ ដល់យើងទៅធ្វើការបានយើងបានលុយណោះអ៊ំយើងបានស្រូវ?

ខ៖ បានស្រូវ។

ក៖ អ៊ំរួចចុះពេលណាដែរគេចាប់ផ្តើមអើដូចជាគេចែកស្រូវចែកអីអោយយើងដើម្បីអោយយើងធ្វើខ្លួនឯងផ្ទាល់ហាស?

ខ៖ យើងធ្វើខ្លួនឯងផ្ទាល់ហោស!

ក៖ បាទ!

ខ៖ អើយូរដែរទំរាំបានធ្វើខ្លួនឯងផ្ទាល់គេចែកស្រែចែកអីអោយហ្នឹងហាស!

កៈ អ៊ូ!

ខៈ យូរ។

កៈ បាទអ៊ុំបាទចុះនៅពេលដែរយើងចាប់ផ្ដើមចាប់ដៃជាមួយស្វាមីដំបូងយើងពិបាកអីទៅ ដោយសារពេលណុងយើងចាប់ផ្ដើមចាយលុយចាយអី?

ខៈ ចាយលុយហើយមកនេះហ្នឹងធំៗមានគ្រួសារ។

កៈ យើងចាប់ដៃគ្នាដំបូងយើងរកស៊ីអីទៅ?

ខៈ កាប់អូសឡ។

កៈ កាប់អូសស្ល?

ខៈ កាប់អូសឡយកមកដាក់លក់វាស់កិបលក់ជំនាន់ណុង។

កៈ អ៊ូតែយើងរកបានតើហ៎ីយើងទៅរកមកពីណាអ៊ុំ?

ខៈ ណោះទៅកាប់ណោះព្រៃបឹងហោស!

កៈ ក្នុងព្រៃហោស?

ខៈ ចាស!

កៈ អ៊ូ!

ខៈ ខែទឹកឡើងចឹងយើងអ៊ុំទូកទៅកាប់មកដាក់មកទឹកស្រកទៅអារដាក់វាបលក់ជំនាន់ណុងគេ មានឡ។

កៈ តែយើងលក់បានថ្លៃដែរណោះ?

ខៈ កាលណុងមួយគីបប៉ុន្មានទេគេវាស់គីប។

កៈ មែនមានតែយើងណាហ៎ីទេទៅរកគេរកច្រើន?

ខៈ អើរកដូចតែគ្នានិងអ្នកស្រុកអ្នកភូមិទៅ។

កៈ យើងប្រជែងគ្នាលក់ហាសណេះ?

ខៈ ចាស!ប្រជែងគ្នាអារលក់ចឹងទៅ។

កៈ អូ៎!

ខៈ ឥឡូវណុងកាលណុងមានអាលែងអាត្រង់សេណឹអីណាអារតែដៃហ្នឹង!

កៈ អូ៎បាទអ៊ុំបាទ!

ខៈ អារឈើ។

កៈ ចុះអ៊ុំគិតថាចឹងពេលណាដែរយើងគិតថាសប្បាយអ៊ុំ?

ខៈ ចាប់ផ្តើមសប្បាយហោសចាប់ផ្តើមសប្បាយដល់ពេលនេះមកនេះទៅហើយទេឆ្នាំប៉ុន្មានហ្នឹងហើយទេចាប់ផ្តើមសប្បាយរហូតមកលែងចាប់កប្រាំលែងអីទៅសប្បាយរហូតអើជួបជុំកូនចៅ។

កៈ អូ៎អាហ្នឹងយើងចាប់ផ្តើមសប្បាយហាសណេះអ៊ុំណេះ?

ខៈ ចាប់ផ្តើមសប្បាយហើយ!

កៈ បាទអ៊ុំបាទចុះអ៊ុំគិតថាអើកាលពីក្មេងអ៊ុំធ្លាប់មានគោលបំណងថាធំឡើងអ៊ុំចង់ធ្វើអីមួយអ៊ុំធ្លាប់គិតអត់ទេអ៊ុំ?

ខៈ អើមិនធ្លាប់គិតអីទេបើថាយើងវាអត់ចេះអក្សរផងនៅតែគិតធ្វើអីហោសធ្វើទស្រែធ្វើតែចំការហ្នឹងហើយគ្មានស្អីទៀតទេ។

កៈ អូ៎បាទអ៊ុំបាទចុះលក្ខណៈថាដូចធ្វើគ្រូពេទ្យ ធ្វើប៉ូលីស ទាហានអីអ៊ុំធ្លាប់គិតអត់ពីមុនគ្រូបង្រៀនអី?

ខៈ គ្មានគិតអីទេបើមិនចេះអក្សរផងទៅគិតធ្វើអីកើត។

កៈ អូ៎បាទអ៊ុំបាទ!

ខៈ ចេះតែដកស្ទូងៗទៅ។

កៈ ចុះបើសិនជាចង់អោយអ៊ុំផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗអ៊ុំមានពាក្យពេចន៍អីដែរចង់ផ្ញើរទៅគាត់អត់អ៊ុំ?

ខៈ ចាស! ខ្ញុំចង់ផ្ដែផ្ដាំណាកូនចៅក្រោយជំនាន់ក្រោយណុងហាសអោយប្រឹងរៀនប្រឹងសូត្រទៅអោយចេះតស៊ូចេះដឹង។

កៈ អ៊ំបាទ!

ខៈ ណេះចៅខ្ញុំមួយនេះធ្វើការអីមិនកើតទេធំឡើងនេះមើលដៃជ្រាយៗម្ចុកៗហេសថាអោយធំឡើងខ្ញុំអោយ..។

កៈ ចុះអើ..?

ខៈ រៀនពេទ្យរៀនអីហ្នឹងគេទៅហោស!

កៈ បាទអ៊ុំចុះអ៊ុំគិតថាអើទាក់ទងពីដូចជាអ៊ុំធ្លាប់ទូន្មានព្រានប្រដៅពួកគាត់អោយធ្វើអំពើល្អដែរ..?

ខៈ ហ្នឹងហើយអោយធ្វើអំពើល្អកុំអោយជក់គ្រឿងញៀនគ្រឿងអីអោយជៀសអោយឆ្ងាយទៅ។

កៈ បាទអ៊ុំបាទត្រូវ។

ខៈ ជក់គ្រឿងញៀនហោស!

កៈ អ៊ុំធ្លាប់ទូន្មានទៅពួកគាត់ដើម្បីអោយគាត់ដើរតាមផ្លូវរបស់អ៊ុំអីអត់?

ខៈ ចាស!

កៈ តាមផ្លូវដែរអ៊ុំចង់សំរេចគោលបំណងប៉ុន្តែអ៊ុំសំរេចអត់ទាន់បានចឹងហាសណាស់?

ខៈ សំរេចមិនទាន់បានចៅតូចពេក។

កៈ ប៉ុន្តែនៅពេលដែរគាត់ធំឡើងចង់អោយគាត់ធ្វើតាមអ្វីដែរ?

ខៈ ចាស!

ក៖ អ៊ុំប៉ងប្រាថ្នាណោះអ៊ុំណោះ?

ខ៖ ហ្នឹងហើយប៉ងប្រាថ្នាចង់អោយធ្វើ។

ក៖ ប៉ុន្តែថៅអត់អីទេណោះអ៊ុំណោះគាត់..?

ខ៖ ថៅខ្ញុំអត់អីទេនៅក្រោយណោះ។

ក៖ អូ៎!

ខ៖ ស្លូតហាស!

ក៖ បាទអ៊ុំបាទចឹងអ៊ុំមានពាក្យពេចន៍អីដែរចង់ផ្តាំផ្ញើរផ្សេងពីហ្នឹងទៀតទេអ៊ុំ?

ខ៖ ដឹងផ្តាំផ្ញើរអីទៀត។

ក៖អូ៎បាទចឹងចុងក្រោយខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំពិភាក្សាជាមួយអ៊ុំទាក់ទងពិប្រវត្តិរបស់អ៊ុំចឹងខ្ញុំមានសំនួរចុងក្រោយមួយបើសិនជាអើខ្ញុំសុំការអនុញ្ញាតិពិអ៊ុំដាក់ការសម្ភាសទាំងអស់ហ្នឹងទៅក្នុងវេបសាយរបស់សាលាបានទេអ៊ុំ?

ខ៖ បានតើ!

ក៖ អូ៎អត់អីទេណោះអ៊ុំណោះ?

ខ៖ ចាស!

ក៖ បាទអ៊ុំបាទ!